00238469

A 190/I/9

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
នៅចំពោះមុខអង្គបុរេជំនុំជម្រះ

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១១) |
| កាលបរិច្ឆេទនៃឯកសារ | ៖ | ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ |
| ភាគីបញ្ជូន | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម | ៖ | អង់គ្លេស |
| ប្រភេទឯកសារ | ៖ | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / NOV / 2008
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

---

## សំណើរបស់សហព្រះរាជអាជ្ញា
## សុំឲ្យមានការណែនាំអំពីសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍

---

**បញ្ជូនដោយ៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

លោក Vincent de WILDE d'ESTMAEL

លោក Anees AHMED

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / NOV / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

**ចែកចាយជូន៖**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គិមសាន

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ភាគីប្តឹងឧទ្ធរណ៍ ខៀវ សំផន៖**

លោក សរ សុវ៉ាន

លោក Jacques VERGES

# សេចក្តីផ្តើម

១. អង្គបុរេជំនុំជម្រះបានណែនាំថា បណ្តឹងឧទ្ធរណ៍នេះត្រូវធ្វើឡើងដោយផ្ទាល់មាត់នៅក្នុងសវនាការសាធារណៈមួយ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៨[1] ។ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពថា អង្គបុរេជំនុំជម្រះ ពិចារណាចេញសំណើចំៗដែលខ្លួនមានចំណងឲ្យភាគីលើកឡើងនៅក្នុងសវនាការនេះ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការធ្វើដូច្នេះនឹងធានាបាននូវ (១) ការត្រៀមរៀបចំសមស្រប និងគ្រប់គ្រាន់របស់ភាគី (២) ផ្តោតលើសេចក្តីអះអាងនានានៅក្នុងអម្លុងពេលសវនាការ និង (៣) ការប្រើប្រាស់ពេលវេលាប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដែលស្តាប់សវនាការស្រដៀងគ្នានេះដែរ តែងមានទម្លាប់ចេញនូវសេចក្តីណែនាំបែបដូច្នេះដែរ[2] ។

២. សហព្រះរាជអាជ្ញាកត់សំគាល់ឃើញថា សវនាការនេះត្រូវបានគេរំពឹងទុកថា មានរយៈពេលតែមួយថ្ងៃប៉ុណ្ណោះ ហើយសុខភាពរបស់របស់ដើមបណ្តឹងឧទ្ធរណ៍ ក៏មិនអាចនឹងធ្វើទៅបានទេ សំរាប់ការអង្គុយរយៈពេលយូរនៅថ្ងៃនោះ។ សំរាប់ហេតុផលទាំងអស់នេះហើយ ទើបសហព្រះរាជអាជ្ញាដាក់ជូនថា ការគ្រោងនូវសំណួរមួយចំនួន នឹងជួយដល់ការកំណត់លើបណ្តឹងឧទ្ធរណ៍បានយ៉ាងមានប្រសិទ្ធភាព ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨

| | |
|---|---|
| **លោក យ៉េត ចរិយា** | **លោក** William SMITH |
| **សហព្រះរាជអាជ្ញារង** | **សហព្រះរាជអាជ្ញារង** |

[1] *ករណីរបស់ ខៀវ សំផន,* សេចក្តីសម្រេចលើពាក្យសុំឲ្យមានសវនាការជាសាធារណៈ របស់លោក ខៀវ សំផន, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ-១១), ចុះថ្ងៃទី០៤ វិច្ឆិកា ២០០៨, A190/I/8 ។

[2] *រដ្ឋអាជ្ញា ទល់នឹង Kajelijeli,* សំណុំរឿងលេខ ICTR-98-44A-A, ដីកាសម្រេចពាក់ព័ន្ធនឹងសវនាការលើបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី១៨ កុម្ភៈ ២០០៥, ទំព័រទី ២ ។ *រដ្ឋអាជ្ញា ទល់នឹង Blaskic,* សំណុំរឿងលេខ IT-95-14-A, ដីកាកំណត់ពេលបើកសវនាការ, ចុះថ្ងៃទី៣១ តុលា ២០០២, ទំព័រទី ២ ។ *រដ្ឋអាជ្ញា ទល់នឹង Brdjanin,* សំណុំរឿងលេខ IT-99-36-A, ដីកាសម្រេចស្តីពីការចោទប្រកាន់, ចុះថ្ងៃទី ២៧ តុលា ២០០៦, ទំព័រទី ២ ។